ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៤ អនក្រ.តត

06 03 2000 15h30 108

# អនុក្រឹត្យ

## ស្តីពីការតែងតាំងសមាសភាព ក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / ៩៤ / ០២ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៦ / ៩៤ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការដាក់មន្ទីរពេទ្យកាល់ម៉ែត ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត ដូចមានរាយនាមខាងក្រោម ÷

១- ឯកឧត្តម ជា ឆាយ ⁄ អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ជា ប្រធានក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត ជំនួសឯកឧត្តម សេង លឹមនៅ ដែលបានទៅទទួលភារកិច្ចថ្មី ។

២- ឯកឧត្តម ម៉ិច សារិន ប្រតិភូរាជរដ្ឋាភិបាល អភិបាលរងរាជធានីភ្នំពេញ ជា សមាជិកក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត ជំនួសឯកឧត្តម ហេ កាន់ ដែលបានទៅទទួលភារកិច្ចថ្មី ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ ២០០០*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ខុទ្ទកាល័យព្រះមហាក្សត្រ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ជូន មន្ទីរពេទ្យកាល់ម៉ែត

រាជធានីភ្នំពេញថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០០០

នាយកខុទ្ទកាល័យ

ឈាងហេង

MINISTERE DE LA SANTE
HOPITAL CALMETTE

ROYAUME DU CAMBODGE
NATION RELIGION ROI

# ORGANIGRAMME

